ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣ សហវ.-អពដ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធ ២០១០

អនុលោមតាមមាត្រា ៥ និងមាត្រា ២៩ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ របស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ទាំងអស់ សូមជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ២០១០ ដូចខាងក្រោម :

១- សហគ្រាសដែលប្រើប្រាស់ឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន (០១ ខែមករា ដល់ ៣១ ខែធ្នូ) ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១០ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១ នៅរដ្ឋបាលសារពើពន្ធដែលមានសមត្ថកិច្ចគ្រប់គ្រងប្រមូលពន្ធលើសហគ្រាស ។

២- សហគ្រាសដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈវេលា ៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ ។

៣- សហគ្រាសដែលមានសាខាច្រើន ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារបស់គ្រឹះស្ថានជាគោលដើមនិងគ្រប់សាខាទាំងអស់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍លទ្ធផលចំណេញ-ខាតរបស់សាខានីមួយៗ ។ គ្រឹះស្ថានដែលជាសាខានីមួយៗ ត្រូវប្រកាសលទ្ធផលចំណេញ-ខាត សាខារបស់ខ្លួនតាមគំរូលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងដាក់ជូនរដ្ឋបាលសារពើពន្ធនៅទីកន្លែងដែលសាខាជាប់ទាក់ទិននីមួយៗតាំងនៅ ។

៤- សហគ្រាសដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គលក) ច្រើន ឬ អនុវត្តគម្រោងដទៃទៀតច្រើនដែលជាគម្រោង គលក ផង និងមិនមែនជា គលក ផង ហើយដែលទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញខុសគ្នា ឬត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដូចមានចែងក្នុងចំណុច ១ ដល់ ៣ ខាងលើ និងត្រូវអនុវត្តតាមការណែនាំបន្ថែមដោយឡែករបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៥- ចំពោះតំណាងអ្នកជាប់ពន្ធដែលទទួលបន្ទុក ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ ជំនួសមុខឱ្យអ្នកជាប់ពន្ធ ត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ដូចមានចែងក្នុងមាត្រា ១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមថ្លែងអំណរគុណចំពោះសហគ្រាសមួយចំនួន ដែលកន្លងមកបំពេញលិខិតប្រកាសពន្ធបានត្រឹមត្រូវ និងដាក់ជូនរដ្ឋបាលសារពើពន្ធទាន់ពេលវេលា ។

ដើម្បីសម្របសម្រួលក្នុងការបំពេញលិខិតប្រកាសឱ្យបានត្រឹមត្រូវ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសៀវភៅពន្យល់ណែនាំសម្រាប់បំពេញលិខិតប្រកាស និងបង្កើតទម្រង់លិខិតប្រកាសជា software ។ ក្នុងករណីលោក-លោកស្រី មានចម្ងល់ផ្សេងៗ សូមទាក់ទងជាមួយការិយាល័យសេវាអ្នកជាប់ពន្ធ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលទាក់ទិន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាស ពិតជាយកចិត្តទុកដាក់ អនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com